# សេចក្តីថ្លែងការណ៍រួម

## បញ្ឈប់អំពើហិង្សា: សេចក្តីអំពាវនាវសុំឲ្យមានការដោះលែង ការស៊ើបអង្កេត និង សំណង

យើងខ្ញុំជាអង្គការសង្គមស៊ីវិលកម្ពុជា និងអន្តរជាតិដែលមានតំណាងក្នុងសេចក្តីថ្លែងការណ៍នេះសូមថ្កោលទោសចំពោះការប្រើកម្លាំងប្រដាប់អាវុធ និងកំណើនអំពើហិង្សាប្រឆាំងនឹងប្រជាពលរដ្ឋកម្ពុជា។

នៅដើមឆ្នាំ ២០១៤ ក្រោយពេលមានបាតុកម្មដោយសន្តិវិធីរយៈពេលបីសប្តាហ៍នៅរាជធានីភ្នំពេញ ភាពតឹងតែងបានកើនឡើងយ៉ាងលឿននៅពេលដែលអាជ្ញាធរបានបង្រ្កាបយ៉ាងសាហាវលើកម្មកររោងចក្រកាត់ដេរ ដែលកំពុងធ្វើបាតុកម្មទាមទារប្រាក់ខែអប្បបរមា ១៦០ ដុល្លារអាមេរិកក្នុងមួយខែ។ ឧស្សាហកម្មកាត់ដេរ ដែលតំណាងឲ្យ ៨០% នៃចំណូលនាំចេញកម្ពុជា មានលក្ខណៈរឹងមាំនិងសំខាន់ជាអន្តរជាតិដោយផលិតសម្លៀកបំពាក់សម្រាប់ស្លាកយីហោល្បីៗពិភពលោក ដូចជា Levis®, H&M, Gap, Puma និង ស្លាកយីហោផ្សេងទៀត។

នៅថ្ងៃទី ៣ ខែ មករា ឆ្នាំ ២០១៤ ជនស៊ីវិល៤នាក់ត្រូវបានបាញ់សម្លាប់ដោយកងកម្លាំងយោធា និងយ៉ាងហោចណាស់៣៩នាក់រងរបួស រួមទាំងក្មេងប្រុសអាយុ ១៧ឆ្នាំម្នាក់ និងស្រ្តីមានគភ៌ម្នាក់ផង និងជនស៊ីវិល១៣នាក់ផ្សេងទៀតត្រូវបានចាប់ខ្លួននៅក្បែរសួនឧស្សាហកម្មកាណាឌីយ៉ា នៅលើផ្លូវវេងស្រេងនៅទីក្រុងភ្នំពេញ។ ឧប្បទ្ទវហេតុ នេះបានកើតឡើងមួយថ្ងៃបន្ទាប់ពីមានការប៉ះទង្គិចគ្នារវាងកងសន្តិសុខ និងកម្មករដែលកំពុងធ្វើកូដកម្មនៅមុខរោងចក្រយ៉ាកជីន នៅលើបណ្តោយផ្លូវជាតិលេខបួនទីដែលមនុស្សដប់នាក់ត្រូវបានចាប់ខ្លួនដោយអង្គភាពបញ្ជាការយោធាពិសេសលេខ ៩១១។ អ្នកដែលត្រូវបានឃាត់ខ្លួន រួមមាន លោក វ៉ន ពៅ អ្នកការពារសិទ្ធិមនុស្សនិងជាប្រធានសមាគមសេដ្ឋកិច្ចក្រៅប្រព័ន្ធឯករាជ្យនិងប្រជាធិបតេយ្យ (IDEA), លោក ថេង សាវឿន មកពីសម្ព័ន្ធភាពសហគមន៍កសិករកម្ពុជា (CCFC) និង លោក ចាន់ ពុទ្ធិស័ក្ក ពីសហគមន៍បឹងកក់ ។ សរុប ជនស៊ីវិលចំនួន ២៣នាក់ត្រូវបានចាប់ខ្លួនដោយកងកម្លាំងប្រដាប់អាវុធ។ អ្នកដែលត្រូវបានឃុំខ្លួនមួយចំនួនត្រូវបានរងការវាយដំយ៉ាងឃោរឃៅ និងដោយពុំទទួលបាននូវការព្យាបាលចាំបាច់អស់រយៈពេលជាច្រើនថ្ងៃ។

ជនដែលត្រូវបានចាប់ខ្លួនទាំងអស់ បានបង្ហាញវត្តមាននៅមុខតុលាការរាជធានីភ្នំពេញនៅថ្ងៃទី ៣ និង ទី ៤ ខែ មករា និង ត្រូវបានចោទប្រកាន់តាម**មាត្រា ២១៨** និង **មាត្រា**

**៥១៩** នៃក្រមព្រហ្មទណ្ឌ (អំពើហិង្សាដោយចេតនាដែលមានស្ថានទម្ងន់ទោស និង ការបំផ្លាញដោយចេតនាដែលមានស្ថានទម្ងន់ទោស)។ បន្ទាប់មក រាជរដ្ឋាភិបាលកម្ពុជាបានព្យួរយ៉ាងជាក់ស្តែងនូវសិទ្ធិមានសេរីភាពនៃការប្រជុំ សមាគម និង បាតុកម្មដោយសន្តិវិធីស្របតាមរដ្ឋធម្មនុញ្ញ ដូចដែលមានចែងក្នុង**មាត្រា ៣៧** និង **មាត្រា ៥១**។

យើងសូមអំពាវនាវដោយទទូចដល់រាជរដ្ឋាភិបាលកម្ពុជា:

- ដោះលែងជនជាប់ឃុំទាំង ២៣ នាក់ជាបន្ទាន់ដោយគ្មានលក្ខខណ្ឌ។
- បង្កើតគណៈកម្មាធិការស៊ើបអង្កេតឯករាជ្យមួយដើម្បីរកមុខរកជនដែលទទួលខុសត្រូវលើអំពើហិង្សានេះ។
- ធានាឲ្យបានថាជនប្រព្រឹត្តត្រូវបានយកមកកាត់ទោសដោយគ្មានបង្អង់ និងផ្តល់សំណងជូនអ្នករងរបួស និង គ្រួសារនៃអ្នកដែលត្រូវគេសម្លាប់។
- បញ្ឈប់ការប្រើអំពើហិង្សានិងកម្លាំងហួសហេតុ ក៏ដូចជាការចាប់ខ្លួនជនស៊ីវិលដោយបំពាន និងផ្ទុយទៅវិញ ធានាឲ្យបាននូវការការពារអ្នករស់នៅកម្ពុជា។
- ស្តារឡើងវិញនិងគោរពរដ្ឋធម្មនុញ្ញ និង ច្បាប់ក្នុងស្រុក ក៏ដូចជាលិខិតូបករណ៍សិទ្ធិមនុស្សអន្តរជាតិដែលរដ្ឋាភិបាលកម្ពុជាបានផ្តល់សច្ចាប័នទាំងអស់ រួមមានគោលការណ៍ជាមូលដ្ឋាននៃអង្គការសហប្រជាជាតិស្តីពីការប្រើកម្លាំងនិងអាវុធដោយមន្ត្រីប្រតិបត្តិច្បាប់ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ (ICCPR) អនុសញ្ញានៃអង្គការពលកម្មអន្តរជាតិ (ILO) និង សេចក្តីប្រកាសជាសកលស្តីពីសិទ្ធមនុស្ស។ រាជរដ្ឋាភិបាលកម្ពុជា ត្រូវតែធានាឲ្យបាននូវការអនុវត្តលទ្ធិប្រជា ធិបតេយ្យ និងសិទ្ធិមនុស្សក្នុងគ្រប់សកម្មភាពរបស់ខ្លួន។

ផ្អែកទៅតាមក្រុមអ្នកតាមដាន ការប៉ះទង្គិចគ្នាបានកើតឡើងនៅពេលដែលរដ្ឋាភិបាលបាន ប្រើដំបងឆក់ទៅលើក្រុមអ្នកតវ៉ា ហើយដែលក្រោយមក ក្រុមអ្នកតវ៉ាទាំងនោះបានឆ្លើយតបដោយការគប់ដុំថ្ម។ កងកម្លាំងប្រដាប់អាវុធបានឆ្លើយតបទៅនឹងសកម្មភាពនេះ ដោយប្រើប្រាស់កម្លាំងមិនមានសមាមាត្រ តាមរយៈបាញ់ដោយកាំភ្លើងគ្រាប់ពិតតម្រង់ទៅរកហ្វូងមនុស្ស។

ការប្រើប្រាស់កម្លាំងទាហានដើម្បីការពារអាជីវកម្មឯកជន និងការបង្ក្រាបលើការតវ៉ានៃជនស៊ីវិល គឺមានលក្ខណៈហួសហេតុ ហើយការប្រើឆ្មាំសន្តិសុខ និង កងកម្លាំងឯកសណ្ឋានស៊ីវិល ដើម្បីចាប់ខ្លួននិងឃាត់ខ្លួនជនស៊ីវិលគឺខុសច្បាប់។ ការប្រើប្រាស់អាវុធបាញ់គ្រាប់ពិតចម្លាម ឧស្ម័នបង្ហូរទឹកភ្នែក ដំបងឆក់អគ្គិសនី ដំបងដែក និង ការបង្ហាញកម្លាំងលើសលុបមិនត្រូវប្រើជាដាច់ខាតប្រឆាំងនឹងជនស៊ីវិល ដែលស្របតាមច្បាប់ មានសិទ្ធិអនុវត្តសិទ្ធិជា

មូលដ្ឋានរបស់ខ្លួន។ ការប្រើកងកម្លាំងរបស់រដ្ឋ ត្រូវតែគោរពយ៉ាងម៉ឺងម៉ាត់តាមគោលការណ៍នីត្យានុកូលភាព ភាពចាំបាច់ និង សមាមាត្រសមស្រប ហើយការធ្វើបាតុកម្ម ត្រូវតែគោរពឲ្យបានជាដាច់ខាតទៅតាមនិយាមអន្តរជាតិ ក្នុងការធានាឲ្យបាននូវសណ្តាប់ធ្នាប់សង្គម។

**យើងខ្ញុំសូមថ្កោលទោសយ៉ាងម៉ឺងម៉ាត់ចំពោះការប្រើប្រាស់កម្លាំងដ៏លើសលុប និងយ៉ាងសាហាវ ការចាប់ខ្លួនដោយបំពាន ការសម្លាប់ និង ការប្រព្រឹត្តិយ៉ាងអមនុស្សធម៌ដោយអាជ្ញាធរកម្ពុជា។**

យើងសូមអំពាវនាវដល់សហគមន៍អន្តរជាតិ ត្រូវចាត់វិធានការជាបន្ទាន់ទៅលើការប្រព្រឹត្តិយ៉ាងអមនុស្សធម៌នេះលើប្រជាពលរដ្ឋកម្ពុជា។

យើងក៏អំពាវនាវផងដែរដល់សមាគមម្ចាស់រោងចក្រកាត់ដេរកម្ពុជា (GMAC) សូមឲ្យបញ្ឈប់សកម្មភាពផ្លូវច្បាប់ប្រឆាំងនឹងសហជីពរោងចក្រកាត់ដេរ។

ជាអាទិភាព យើងសូមលើកទឹកចិត្តដល់បុគ្គលិកស្ថានទូតអន្តរជាតិ ទៅសួរសុខទុក្ខជនជាប់ឃុំក្នុងពន្ធនាគារ ដើម្បីធានាឲ្យបាននូវសុខុមាលភាពនៃជនជាប់ឃុំទាំងនោះ។

យើងសូមអំពាវនាវដល់ក្រុមហ៊ុនវាយ្សនភណ្ឌអន្តរជាតិ ពិចារណាការទាមទាររបស់កម្មកររោងចក្រកាត់ដេរដើម្បីទទួលបាននូវការតម្លើងប្រាក់ខែគោល និងកែលំអលក្ខណ្ឌការងាររបស់ពួកគេ។

យើង ដែលជាអង្គការសង្គមស៊ីវិលចំនួន ១៨១ ដែលបានចុះហត្ថលេខាខាងក្រោម ជឿថាអំពើហិង្សាប្រឆាំងនឹងប្រជាពលរដ្ឋមិនអាចទទួលយកបានជាដាច់ខាត។

សេចក្តីថ្លែងការណ៍នេះ ត្រូវបានគាំទ្រដោយអង្គការសង្គមស៊ីវិលកម្ពុជានិងអន្តរជាតិខាងក្រោម:

1. ACR/CARITAS AUSTRALIA
2. A141Skun community (Siem Reap)
3. Action for Environment and Community (AEC)
4. Advocacy and Policy Institute (API)
5. Alliance Action for Rural Restoration Organization (AARR)
6. Anlung Treng community (Kompong Som)
7. ASEAN services Employees Trade Union council
8. ASEAN Youth Assembly (AYA)
9. ASEAN Youth Council (AYC) - Myanmar
10. ASEAN Youth Movement (AYM) - Myanmar
11. Asia Pacific Research Network (APRN)

12. Asia Pacific Solidarity Coalition (APSOC)
13. Asian Muslim Action Network ( AMAN) Indonesia
14. Banteay Srei
15. Boat People SOS
16. Bread for the World
17. Buddhism for Social Development Action (BSDA)
18. Buddhism Foundation For Community Development (BFCD)
19. Building Community Voices (BCV)
20. Burma Pastuership (BP)
21. C E Pram 5 community (Kompong Som)
22. CamASEAN Youth Future (CamASEAN)
23. Cambodia Indigenous Youth Association (CIYA)
24. Cambodia Organization to Promote Kui Culture (OPKC)
25. Cambodia Women Crisis Center (CWCC)
26. Cambodian Center for Independent Media (CCIM)
27. Cambodian Defender Project (CDP)
28. Cambodian Food and Service Worker Federation (CFSWF)
29. Cambodian HIV/AIDS Education and Care (*CHEC*)
30. Cambodian Human Rights Action Committee (CHRAC)
31. Cambodian Human Rights Task Force (CHRTF)
32. Cambodian Independent Teacher Association (CITA)
33. Cambodian League for the Promotion and Defense of Human Rights (LICADHO)
34. Cambodian Men Network (CMN)
35. Cambodian Organization for Children and Development (COCD)
36. Cambodian Rural Development Team (CRDT)
37. Cambodian Volunteers for Society (CVS)
38. Cambodian Youth Network (CYN)
39. Cambodian Human Rights and Development Association (ADHOC)
40. Cambodian Labour Confederation (CLC)
41. Center for Labor Rights of Cambodia (CLARI)
42. Chapter - 8 - Myanmar
43. Chi Kreng community (Siem Reap)
44. Children and Life Association (CLA)
45. Childwise Cambodia
46. Christian for Social Justice (CSJ)
47. Coalition of Cambodian Apparel Workers's Democratic Union (C.CAWDU)
48. Coalition of Cambodian Farmer's Community (CCFC)
49. Coalition to Abolish Modern-day Slavery in Asia (CAMSA)
50. Coastal Fisherfolk Network (Kampot, Kep, Kompong Som, Koh Kong)
51. Committee to Promote Women in Politics (CPWP)
52. Community Capacities for Development (CCD)
53. Community Legal Education Center (CLEC)
54. Community Organization for People's Action (COPA)
55. Community Peace-Building Network (CPN)
56. Cooperation Committee for Cambodia (CCC)
57. DanChurchAid/ChristianAid (DCA/CA)
58. DANMISSION
59. Development for People of Cambodia (DPC)

60. Diakonia
61. East West Management Institute (EWMI)
62. Empowering Youth in Cambodia (EYC)
63. Equitable Cambodia (EC)
64. Farmer Community Network Kampot
65. Farmer Community Network Takeo
66. Farmer Nature Network (FNN)
67. Finn Church Aid / Asia
68. Forum Syd
69. Four Regions Slum Network (FRSN)
70. Free Trade Union of Worker of Cambodia (FTUWC)
71. GABRIELA Philippines
72. Gender and Development for Cambodia (GAD/C)
73. HEKS
74. Highlanders Association-Ratanakiri (HA-RTK)
75. Housing Rights Task Force (HRTF)
76. Human Rights Ambassador for Salem-News.com, UK
77. Human Rights Defenders and Promoters Network (HRDP)
78. Human Settlement Foundation (HSF)
79. Inclusive Development International (IDI)
80. Independent Democracy of Informal Economy Association(IDEA)
81. Independent Monk for Justice and Peace Network (IMNSJ)
82. Indigenous Community Support Organization (ICSO)
83. Indonesian Human Rights Monitor (IHRM)
84. Initiatives for International Dialogue (IID)
85. Interfaith Youth Coalition on AIDS in Myanmar (IYCA-Myanmar)
86. International NGO Forum on Indonesia Development
87. International Volunteers of Yamagata (IVY)
88. Investing in Children and their Societies (ICS)
89. K'bal Hong community (Kompong Som)
90. Kdei Karuna
91. Kepa (Finnish NGO platform and an expert organisation working with global development issues)
92. Khlaing Leu community (Kompong Som)
93. Khmer Ahimsa (KAH)
94. Khmer Akphiwat Khmer Organization (KAKO)
95. Khmer Association For Development Of Country-side Cambodia (KAFDOC)
96. Khmer Civilization Foundation (KCF)
97. Khmer Institute for National Development (KIND)
98. Khmer Kampuchea Krom For Human Rights and Development Association (KKKHRDA)
99. Khmer Youth and Social Development (KYSD)
100. Khmer Youth Association (KYA)
101. Korean Missionary Society (KOMISO)
102. Land Communities Network (Kandal)
103. Leaders and Organizers of Community Organizations in Asia (LOCOA)
104. Legal Support for Children and Women (LSCW)
105. LICADHO-CANADA
106. Life with Dignity (LWD)
107. MARUAH( Working Group for ASEAN Human Rights Mechanism, Singapore)

108. Messenger Band (United Sisterhood)
109. MIT - Myanmar
110. Monitoring Evaluation & Research Institute (MERI)
111. Morodok
112. My Village
113. Network of the Councils of Mekong Tambon Community Organization in Thailand's 7 Northeastern Provinces
114. Neutral & Impartial Committee for Free & Fair Elections in Cambodia (NICFEC)
115. New Hope Cambodia (NHC)
116. NGO Coalition on the Rights of the Child (NGOCRC)
117. NGO Education Partnership (NEP)
118. NGO Forum on Cambodia (NGOF)
119. NGO Gender Group (NGOGG) - Myanmar
120. Northeastern People Council (NPC) - Thailand
121. Northeastern People's Network to Protect their Native Land (NNPNL) - Thailand
122. Norwegian People's Aid (NPA)
123. O Kampuchea community (Kompong Som)
124. Oral Network (Kompong Speu)
125. Oxfam
126. PACT
127. Partnership for Development in Kampuchea (PADEK)
128. People Action for Change (PAC)
129. People Center for Development and Peace (PDP)
130. People in Need-Cambodia
131. People's Forum on Cambodia (PEFOC, J)
132. Phnom Kouk Network (Kompong Chnang, Pursat)
133. Ponleu Ney Kdey Sangkhum (PNKS)
134. Ponlok Khmer
135. Prek Trey community (Kompong Som)
136. Riverkids Foundation
137. Sahmakum Teang Tnaut (STT)
138. Sarawak Dayak Iban Association (SDIA)
139. Shwe Has Momyt (SHM) - Myanmar
140. SILAKA
141. Sna Sangkream community (Siem Reap)
142. Snoul community (Kratie)
143. Social Action for Change (United Sisterhood)
144. Spean Che community (Kompong Som)
145. STAR Kampuchea (SK)
146. Strey Khmer (SK)
147. Sugar Justice Network (Kompong Speu, Koh Kong, Oddar Meanchey)
148. Tabaing Keut community (Siem Reap)
149. Tabaing Lech community (Siem Reap)
150. Taiwan Association for Human Rights (TAHR)
151. Taksvarkki ry (ODW Finland)
152. Tani community (Siem Reap)
153. Tapaen community (Siem Reap)
154. Terre des Hommes Germany

155. Thai Poor Act (TPA)
156. The Cambodian Center for the Protection of Children's Rights ( CCPCR)
157. The Committee for Free and Fair Elections in Cambodia (COMFREL)
158. Think Centre - Singapore
159. Tonle Sap Network
160. Towards Ecological Recovery and Regional Alliance (TERRA)
161. Transparency International (TI)
162. Urban Poor Women Development (UPWD)
163. Veal Chanty community (Kompong Som)
164. Volunteer for Sustainable Development (VSD)
165. Welthungerhilfe
166. WomanHealth Philippines
167. Women Corp of Indonesian Moslem Student Movement (KOPRI)
168. Women Peace Maker (WPM)
169. Women's Legal and Human Rights Bureau (WLB) - Philippines
170. Women's Network for Unity (United Sisterhood)
171. Women's Organizations Network of Myanmar (WON)
172. Woment's Media Center of Cambodia
173. Worker Hub for Chane
174. Worker's Information Centre (United Sisterhood)
175. Working Group for Partnerships in Decentralisation (WGPD)
176. Working Group for Peace (WGP)
177. World Renew
178. Yayasan LINTAS NUSA - Batam - Indonesia
179. Youth Council of Cambodia (YCC)
180. Youth For Peace (YFP)
181. Youth Resource Development Program (YRDP)